រុក្ខជាតិដុះជ្រែករាលដាលដែលត្រូវបានរឹតត្បិត

# កញ្ឆែត

*Neptunia oleracea* ឬ *Neptunia plena*



**អ្នកមិនត្រូវដាំ លក់ ឬឲ្យរុក្ខជាតិនេះទៅអ្នកណាឡើយ។ មានរុក្ខជាតិដទៃដែលគេអាចជំនួសវាបានសម្រាប់ប្រើធ្វើម្ហូប។**

ប្រសិនបើអ្នកជឿថាអ្នកបានឃើញកញ្ឆែត អ្នកត្រូវតែរាយការណ៍ទៅការិយាល័យ Biosecurity Queensland ដោយទូរស័ព្ទទៅលេខ ១៣ ២៥ ២៣។

ការិយាល័យ Biosecurity Queensland នឹងផ្តល់ឱវាទ ឬជំនួយអំពីរបៀបគ្រប់គ្រងរុក្ខជាតិនេះ។ ជនណាដែលរកឃើញកញ្ឆែត ត្រូវខ្នះខ្នែងចាត់ចែងកុំឲ្យកញ្ឆែតនោះរីករាលដាល។

កញ្ឆែតបង្កឲ្យមានបញ្ហាខ្ពស់បំផុតដល់ផ្លូវទឹកនិងដីជាំទឹករបស់រដ្ឋឃ្វីនស្លែន។ វាដុះចេញពីគែមផ្លូវទឹកហូរ បង្កើតជាក្បូនអណ្តែតទឹកជាច្រើន។

ក្បូនអណ្តែតទឹកទាំងនោះអាចធ្វើឲ្យទឹកដែលហូរក្នុងព្រែកបន្លាយ និងលូមានភាពស្ទះចង្អៀត។

ក្បូនទាំងនេះទៅជាកកកុញខ្លាំងដែលអាចធ្វើឲ្យគុណភាពទឹកមានការថយចុះ បង្កើតកន្លែងឲ្យមូសស្រួលរស់នៅ ហើយនិងបង្កឲ្យស្លាប់រុក្ខជាតិជម្ងជាតិ រុក្ខជាតិក្នុងទឹក ហើយនិងត្រី។

Queensland Government

## តម្រូវការតាមលក្ខណៈច្បាប់

កញ្ឆែត (*Neptunia oleacea* និង *Neptunia plena*) ជាប្រភេទ
២ ៣ ៤ និង ៥
នៃរុក្ខជាតិដុះជ្រែករាលដាលដែលត្រូវបានរិតត្បិតក្រោមច្បាប់
*Biosecurity Act 2014* ។

គេមិនត្រូវរក្សាកញ្ឆែត យកពីកន្លែងមួយទៅកន្លែងមួយ
ផ្តល់ឲ្យគេ លក់ ឬបោះលែងទៅក្នុងបរិស្ថានឡើយ។
ប្រសិនបើអ្នករកឃើញកញ្ឆែត
អ្នកត្រូវតែរាយការណ៍អំពីវាទៅការិយាល័យ Biosecurity
Queensland ដោយទូរស័ព្ទទៅលេខ ១៣ ២៥ ២៣
ក្នុងរយៈពេល ២៤ ម៉ោង។
ប្រសិនបើអ្នកមិនបានរាយការណ៍អំពីវត្តមានរបស់កញ្ឆែត
នោះទៅការិយាល័យ Biosecurity Queensland ទេ
អ្នកអាចត្រូវពិន័យ
រួមទាំងការផាកពិន័យនៅកន្លែងនោះតែម្តងផង។

## សេចក្តីរៀបរាប់

កញ្ឆែតជារុក្ខជាតិដុះអណ្តែតទឹកដែលជាប់ទៅនឹងច្រាំងនៅ
មាត់ទឹក។ ដើមវាស្នោតៗលូតផុតលើផ្ទៃទឹក។
ប្រភេទម្យ៉ាងដែលមានឫសដុះលើដី(ប្រក្រាប)មានស្លឹកនិង
ផ្កាតូចៗ ពុំមានទងស្នោតៗអណ្តែតលើទឹកទេ។

ស្លឹកវានៅជាពីរជួរទល់មុខគ្នាសងខាងទង។
ពេលគេរំខានឬប៉ះវា ស្លឹកទាំងនោះឡើងខ្ទប។
ផ្ការបស់កញ្ឆែតមានពណ៌លឿង ជាដុំមូលៗដូចបាល់
ដុះចេញពីគល់ស្លឹក។

## ដំណើរវិលជុំនៃជីវិត

កញ្ឆែតអាចដុះចេញពីគ្រាប់
ហើយនិងពីផ្នែកនានានៃទងដែលបាក់ដាច់ចេញពីដើមមេ
។
គ្រាប់ឬកំទេចទងដែលបាក់ទាំងឡាយធ្វើដំណើរតាមទឹក(
ជាពិសេសនៅពេលមានទឹកជំនន់)។
ដើមថ្មីទាំងពួងនឹងកកើតនៅទីក្រោមៗដែលទឹកហូរទៅ។
ផ្កាចាប់ផ្តើមមាននៅដើមរដូវក្តៅ។

## ទីកន្លែងដែលមានដុះនិងការចែកចាយ

កញ្ឆែតមានដុះជាធម្មជាតិនៅតំបន់ត្រូពិច (Tropical)នៃទ្វីបអាស៊ី
អាហ្វ្រិក និងអាមេរិកខាងត្បូង។ វាដុះជាព្រៃនៅតំបន់ទាំងនោះ
ហើយមានគេធ្វើការដាំដុះវាសម្រាប់ធ្វើជាបន្លែនៅទូទាំងអាស៊ីអា
គ្នេយ៍ ជាពិសេសប្រទេសថៃ និងឥណ្ឌូចិន។ គួរឲ្យសោកស្តាយ
កញ្ឆែតអាចធ្វើឲ្យខូចខាតដល់ផ្លូវទឹករបស់រដ្ឋឃ្វីនស្លែន
ហើយត្រូវបានកំណត់ឲ្យមានការកំចាត់ចោលនៅរដ្ឋឃ្វីនស្លែន។

## ព័ត៌មានបន្ថែម

មានព័ត៌មានបន្ថែមពីការិយាល័យរដ្ឋាភិបាលមូលដ្ឋានរបស់
លោកអ្នក ឬតាមការទូរស័ព្ទទៅលេខ ១៣ ២៥ ២៣
ឬចូលទៅ biosecurity.qld.gov.au.









© The State of Queensland, Department of Agriculture and Fisheries, 2022. 